ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៣៦ . អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគដីព្រៃបម្រុងទុករអចិន្ត្រៃយ៍របស់រដ្ឋលើផ្ទៃដីទំហំ ២.១១១ ហិកតា សម្រាប់សម្បទានដីសង្គមកិច្ច ស្ថិតនៅសង្កាត់កូនក្រៀល ក្រុងសំរោង ខេត្តឧត្តរមានជ័យ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## ស ម្រេ ច

**មាត្រា ១:-**

ត្រូវបានចាត់ថ្នាក់ជាផ្ទៃដីព្រៃសម្រាប់ផ្ទេរ ដើម្បីគោលបំណងអភិវឌ្ឍផ្សេងទៀត នូវដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ លើផ្ទៃដីទំហំ ២.១១១ (ពីរពាន់មួយរយដប់មួយ) ហិកតា ដែលមានទីតាំងស្ថិតក្នុងសង្កាត់កូនក្រៀល ក្រុងសំរោង ខេត្តឧត្តរមានជ័យ ដូចមានផែនទីផ្ជូនភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យ ហើយកំណត់ដោយបណ្តាចំណុចគោលដែលមាននិយាមកា ដូចខាងក្រោម ៖

A (៣៥០២៨៦, ១៥៨៦១៩២) B (៣៥០២៨១, ១៥៨៧៩៨៦) C (៣៤៧៩៣៤, ១៥៨៧៩៩៥)
D (៣៤៨៥៦៦, ១៥៩០៤២២) E (៣៤៨៤០៥, ១៥៩១០៤២) F (៣៤៩១១៩, ១៥៩០៩៨៦)
G (៣៥០៣១០, ១៥៨៩៣៩៥) H (៣៥០៦៦០, ១៥៨៩០៨១) I (៣៥១៧១០, ១៥៩០៥៦៦)
J (៣៥១៦២២, ១៥៩១១២២) K (៣៥២១៤១, ១៥៩១០៧១) L (៣៥៣១០៧, ១៥៩២០២៩)
M (៣៥៣៧៣៥, ១៥៩២៣៣៣) N (៣៥៤៧៦៥, ១៥៩២៨៤០) O (៣៥៥០៨១, ១៥៩២៧២២)
P (៣៥៥០១៨, ១៥៩២៥៣៥) Q (៣៥៥៩១២, ១៥៩២៥៥៨) R (៣៥៦០៩១, ១៥៩២១៤១)
S (៣៥៥០២៨, ១៥៩០៧៤១) T (៣៥២៤៣០, ១៥៨៧៤៦៧) ។

**មាត្រា ២:-**

ត្រូវបានធ្វើអនុបយោគផ្ទៃដីទំហំ ពីរពាន់មួយរយដប់មួយ (២.១១១ ហិកតា) ដូចមានចែងក្នុងមាត្រា ១ នៃអនុក្រឹត្យនេះ ដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ។

**មាត្រា ៣:-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ដីឯកជនរបស់រដ្ឋទំហំ ពីរពាន់មួយរយដប់មួយ (២.១១១ ហិកតា) ដូចមានចែងក្នុងមាត្រា ២ នៃអនុក្រឹត្យនេះ ប្រគល់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ដីរដ្ឋដើម្បីចុះបញ្ជីជាដីឯកជនរបស់រដ្ឋ សម្រាប់ផ្តល់ជាសម្បទានដីសង្គមកិច្ចធ្វើជាតំបន់អភិវឌ្ឍន៍យោធិនរបស់គណៈបញ្ជាការឯកភាពសមរភូមិទិសទី៣ ស្របតាមច្បាប់ គោលការណ៍របស់រាជរដ្ឋាភិបាល និងតម្រូវការជាក់ស្តែង ។

**មាត្រា ៤:-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥:-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលខេត្តឧត្តរមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u> :

ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ, កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ១៣៦ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ២០១១ ស្តីពីការធ្វើអនុបយោគដីព្រៃបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋសម្រាប់សម្បទានដីសង្គមកិច្ច

ស្ថិតនៅ សង្កាត់គូនក្រៀល ក្រុងសំរោង ខេត្តឧត្តរមានជ័យ




សញ្ញាសំគាល់ :

- ● ចំនុចគោលព្រំដី
- ព្រំប្រទល់ដី
- ព្រំប្រទល់សហគមន៍ព្រៃឈើ

COORDINATE SYSTEM
Projection: UTM
Zone: 48
Horizontal Datum: Indian 1960
Spheroid: Everest
UTM Grid: 1 Km

មាត្រដ្ឋាន ១ : ៥០ ០០០

| Name | Coor_x | Coor_y |
|---|---|---|
| A | 350246 | 1586192 |
| B | 350281 | 1587986 |
| C | 347934 | 1587995 |
| D | 348566 | 1590422 |
| E | 348405 | 1591042 |
| F | 349119 | 1590986 |
| G | 350310 | 1589395 |
| H | 350660 | 1589081 |
| I | 351710 | 1590566 |
| J | 351622 | 1591122 |
| K | 352141 | 1591071 |
| L | 353107 | 1592029 |
| M | 353735 | 1592333 |
| N | 354765 | 1592840 |
| O | 355081 | 1592722 |
| P | 355018 | 1592535 |
| Q | 355912 | 1592558 |
| R | 356091 | 1592141 |
| S | 355028 | 1590741 |
| T | 352430 | 1587467 |